ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២០២ ព.ណ.ខាណ.ប្រក

# ប្រកាស
## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន អឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងពាណិជ្ជកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១** :

នាយកដ្ឋានអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ មានមុខងារ និងភារកិច្ចដូចតទៅៈ

- ធ្វើសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយទ្វីបអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក
- ស្រាវជ្រាវ និងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព សម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មទ្វេភាគី និងតំបន់
- សហការជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ ដើម្បីចរចាបើកច្រកទីផ្សារ សម្រួល និងជំរុញពាណិជ្ជកម្មនៅក្នុងទ្វីបអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក



ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA
ទូរស័ព្ទ / ទូរសារ:(៨៥៥)-២៣ ៨៦៦ ៤៦៩
Phone/Facsimile: (855)-23 866 469

- ប្រតិបត្តិរាល់នយោបាយ និងបេសកកម្មរបស់ក្រសួង ក្នុងការគ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិជាមួយបណ្តាប្រទេសនៅក្នុងទ្វីបអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក
- សម្របសម្រួលជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ ដោះស្រាយបញ្ហាទាក់ទងនឹងរបាំងពន្ធគយ និងមិនមែនពន្ធគយ សំដៅសម្រួលការធ្វើពាណិជ្ជកម្មជាមួយបណ្តាប្រទេសនៅទ្វីបអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក
- ផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋាន និងកិច្ចព្រមព្រៀងពាណិជ្ជកម្មរបស់កម្ពុជាជាមួយបណ្តាប្រទេសនៅទ្វីបអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក
- សម្របសម្រួល និងជំរុញការអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈនៃការយោគយល់គ្នារបស់កម្ពុជា ក្នុងក្របខ័ណ្ឌទ្វេភាគី និងតំបន់ជាមួយបណ្តាប្រទេសនៅទ្វីបអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក
- សហការជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ រៀបចំកម្មវិធីបណ្តុះបណ្តាល កសាងសមត្ថភាព និងរៀបចំកិច្ចប្រជុំ សិក្ខាសាលា វេទិកា និងផ្សព្វផ្សាយលទ្ធផលនៃការចរចាបើកច្រកទីផ្សារសម្រាប់ទំនិញ សេវាកម្ម សន្ធិសញ្ញា និងកិច្ចព្រមព្រៀងដទៃទៀត ជូនដល់មន្ត្រីរាជការ សិស្ស និស្សិត និងវិស័យឯកជន
- ស្រាវជ្រាវ និងចងក្រងព័ត៌មាន និងទិន្នន័យពាណិជ្ជកម្ម ក្នុងក្របខ័ណ្ឌទ្វីបអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក
- សម្របសម្រួល និងសហការជាមួយអង្គការ សមាគម និងសភាពាណិជ្ជកម្មក្នុងក្របខ័ណ្ឌទ្វីបអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ២** :

នាយកដ្ឋានអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ ៣** :

នាយកដ្ឋានអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក មានការិយាល័យចំណុះចំនួន៣ គឺ៖

១- ការិយាល័យអឺរ៉ុប

២- ការិយាល័យមជ្ឈឹមបូព៌ា

៣- ការិយាល័យអាហ្វ្រិក

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ ៤** :

ការិយាល័យអឺរ៉ុប មានភារកិច្ច៖

- ធ្វើសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយបណ្តាប្រទេសក្នុងទ្វីបអឺរ៉ុប

- ស្រាវជ្រាវ និងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព សម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មទ្វេភាគី និងតំបន់
- សហការជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ ដើម្បីចរចាបើកច្រកទីផ្សារ សម្រួល និងជំរុញពាណិជ្ជកម្មនៅក្នុងទ្វីបអឺរ៉ុប
- ប្រតិបត្តិរាល់នយោបាយ និងបេសកកម្មរបស់ក្រសួង ក្នុងការគ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិជាមួយបណ្តាប្រទេសនៅក្នុងទ្វីបអឺរ៉ុប
- សម្របសម្រួលជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ ដោះស្រាយបញ្ហាទាក់ទងនឹងរបាំងពន្ធគយ និងមិនមែនពន្ធគយ សំដៅសម្រួលការធ្វើពាណិជ្ជកម្មជាមួយបណ្តាប្រទេសនៅទ្វីបអឺរ៉ុប
- ផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋាន និងកិច្ចព្រមព្រៀងពាណិជ្ជកម្មរបស់កម្ពុជា ជាមួយបណ្តាប្រទេសនៅទ្វីបអឺរ៉ុប
- សម្របសម្រួល និងជំរុញការអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈនៃការយោគយល់គ្នារបស់កម្ពុជា ក្នុងក្របខ័ណ្ឌទ្វេភាគី និងតំបន់ជាមួយបណ្តាប្រទេសនៅទ្វីបអឺរ៉ុប
- សហការជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ រៀបចំកម្មវិធីបណ្តុះបណ្តាល កសាងសមត្ថភាព និងរៀបចំកិច្ចប្រជុំ សិក្ខាសាលា វេទិកា និងផ្សព្វផ្សាយលទ្ធផលនៃការចរចាបើកច្រកទីផ្សារសម្រាប់ទំនិញ និងសេវាកម្ម សន្ធិសញ្ញា និងកិច្ចព្រមព្រៀងដទៃទៀតក្នុងក្របខ័ណ្ឌទ្វីបអឺរ៉ុប ជូនដល់មន្ត្រីរាជការ សិស្ស និស្សិត និងវិស័យឯកជន
- ស្រាវជ្រាវ និងចងក្រងព័ត៌មាន និងទិន្នន័យពាណិជ្ជកម្ម ក្នុងក្របខ័ណ្ឌទ្វីបអឺរ៉ុប
- សហការជាមួយតំណាងសហភាពអឺរ៉ុបនៅកម្ពុជា និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ពិនិត្យ និងតាមដានវឌ្ឍនភាពនៃការអនុវត្តកិច្ចព្រមព្រៀងសហប្រតិបត្តិការកម្ពុជា និងសហភាពអឺរ៉ុប ឯកសារយុទ្ធសាស្ត្រកម្ពុជា និងសហភាពអឺរ៉ុប និងកម្មវិធីជំនួយអភិវឌ្ឍន៍របស់សហភាពអឺរ៉ុប រួមមានឧបករណ៍សហប្រតិបត្តិការអភិវឌ្ឍន៍
- សម្របសម្រួល និងសហការជាមួយអង្គការ សមាគម និងសភាពាណិជ្ជកម្មក្នុងទ្វីបអឺរ៉ុប
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៥** :

ការិយាល័យមជ្ឈឹមបូព៌ា មានភារកិច្ចៈ

- ធ្វើសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយបណ្តាប្រទេសនៅមជ្ឈឹមបូព៌ា
- ស្រាវជ្រាវ និងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព សម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មទ្វេភាគី និងតំបន់
- សហការជាមួយអង្គភាពនិងស្ថាប័នពាក់ព័ន្ធ ដើម្បីចរចាបើកច្រកទីផ្សារ សម្រួល និងជំរុញពាណិជ្ជកម្មនៅមជ្ឈឹមបូព៌ា

- ប្រតិបត្តិរាល់នយោបាយ និងបេសកកម្មរបស់ក្រសួង ក្នុងការគ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិជាមួយបណ្តាប្រទេសនៅមជ្ឈឹមបូព៌ា
- សម្របសម្រួលជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ ដោះស្រាយបញ្ហាទាក់ទងនឹងរបាំងពន្ធគយ និងមិនមែនពន្ធគយ សំដៅសម្រួលការធ្វើពាណិជ្ជកម្មជាមួយបណ្តាប្រទេសនៅមជ្ឈឹមបូព៌ា
- ផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋាន និងកិច្ចព្រមព្រៀងពាណិជ្ជកម្មរបស់កម្ពុជាជាមួយបណ្តាប្រទេសនៅមជ្ឈឹមបូព៌ា
- សម្របសម្រួល និងជំរុញការអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈនៃការយោគយល់គ្នារបស់កម្ពុជា ក្នុងក្របខ័ណ្ឌទ្វេភាគី និងតំបន់ជាមួយបណ្តាប្រទេសនៅមជ្ឈឹមបូព៌ា
- សហការជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ រៀបចំកម្មវិធីបណ្តុះបណ្តាល កសាងសមត្ថភាព និងរៀបចំកិច្ចប្រជុំ សិក្ខាសាលា វេទិកា និងផ្សព្វផ្សាយលទ្ធផលនៃការចរចាបើកច្រកទីផ្សារសម្រាប់ទំនិញ និងសេវាកម្ម សន្ធិសញ្ញា និងកិច្ចព្រមព្រៀងដទៃទៀតនៅមជ្ឈឹមបូព៌ាជូនដល់មន្ត្រីរាជការ សិស្ស និស្សិត និងវិស័យឯកជន
- ស្រាវជ្រាវ និងចងក្រងព័ត៌មាន និងទិន្នន័យពាណិជ្ជកម្ម នៅមជ្ឈឹមបូព៌ា
- សម្របសម្រួល និងសហការជាមួយអង្គការ សមាគម និងសភាពាណិជ្ជកម្មនៅមជ្ឈឹមបូព៌ា
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៦** :

ការិយាល័យអាហ្វ្រិក មានភារកិច្ចៈ

- ធ្វើសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយបណ្តាប្រទេសនៅទ្វីបអាហ្វ្រិក
- ស្រាវជ្រាវ និងរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព សម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មទ្វេភាគី និងតំបន់
- សហការជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ ដើម្បីចរចាបើកច្រកទីផ្សារ សម្រួល និងជំរុញពាណិជ្ជកម្មនៅទ្វីបអាហ្វ្រិក
- ប្រតិបត្តិរាល់នយោបាយ និងបេសកកម្មរបស់ក្រសួង ក្នុងការគ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិជាមួយបណ្តាប្រទេសនៅទ្វីបអាហ្វ្រិក
- សម្របសម្រួលជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ ដោះស្រាយបញ្ហាទាក់ទងនឹងរបាំងពន្ធគយ និងមិនមែនពន្ធគយ សំដៅសម្រួលការធ្វើពាណិជ្ជកម្មជាមួយបណ្តាប្រទេសនៅទ្វីបអាហ្វ្រិក
- ផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋាន និងកិច្ចព្រមព្រៀងពាណិជ្ជកម្មរបស់កម្ពុជាជាមួយបណ្តាប្រទេសនៅទ្វីបអាហ្វ្រិក

- សម្របសម្រួល និងជំរុញការអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈនៃការយោគយល់គ្នារបស់កម្ពុជា ក្នុងក្របខ័ណ្ឌទ្វេភាគី និងតំបន់ជាមួយបណ្តាប្រទេសនៅទ្វីបអាហ្វ្រិក
- សហការជាមួយអង្គភាព និងស្ថាប័នពាក់ព័ន្ធ រៀបចំកម្មវិធីបណ្តុះបណ្តាល កសាងសមត្ថភាព និងរៀបចំកិច្ចប្រជុំ សិក្ខាសាលា វេទិកា និងផ្សព្វផ្សាយលទ្ធផលនៃការចរចាបើកច្រកទីផ្សារសម្រាប់ទំនិញ និងសេវាកម្ម សន្ធិសញ្ញា និងកិច្ចព្រមព្រៀងដទៃទៀតនៅទ្វីបអាហ្វ្រិកជូនដល់មន្ត្រីរាជការ សិស្ស និស្សិត និងវិស័យឯកជន
- ស្រាវជ្រាវ និងចងក្រងព័ត៌មាន និងទិន្នន័យពាណិជ្ជកម្ម នៅទ្វីបអាហ្វ្រិក
- សម្របសម្រួល និងសហការជាមួយអង្គការ សមាគម និងសភាពាណិជ្ជកម្មនៅទ្វីបអាហ្វ្រិក
- ទទួលបន្ទុកការងាររដ្ឋបាល និងសម្របសម្រួលការងារទូទៅរបស់នាយកដ្ឋាន
- គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពព័ត៌មានចូលទៅក្នុងវេបសាយ និងគេហទំព័រនាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៧** :

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានអង្គភាពចំណុះក្រសួង ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែ កក្កដា ឆ្នាំ២០១៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ស៊ុន ចាន់ថុល**

<u>**កន្លែងទទួល៖**</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងមុខងារសាធារណៈ
-ដូចប្រការ៧
-ឯកសារ-កាលប្បវត្តិ

# រចនាសម្ព័ន្ធនាយកដ្ឋានអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក

